ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ និងឈ្មោះសំណុំរឿង ៖ ១១១/១១-ឡុង លីដ
កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ ៖ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១១

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្ដីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក: អ៊ុង សុទ្ធី
អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: លីវ សុវណ្ណា
ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ: រុន សារ៉ាយ

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ឡុង លីដ (ខេមបូឌា)**
អាសយដ្ឋាន ៖ ភូមិចំការស្វាយ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង
ទូរស័ព្ទ ៖ ០១៦ ៦៤៧ ៦៣៨ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖
១-កញ្ញា ឯក ផាន់ណា ប្រធានរដ្ឋបាល
២-លោក យឹម ជឿង ជំនួយការរដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **-សហព័ន្ធសហជីពយុវជនខ្មែរ**
**-សហជីពយុវជនខ្មែរក្រុមហ៊ុន ឡុង លីដ**
អាសយដ្ឋាន ៖ ភូមិចំការស្វាយ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង
ទូរស័ព្ទ ៖ ០១២ ៩៤០ ៥៤៨ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

| | |
|---|---|
| ១-លោក ម៉ៃ វឌ្ឍនា | អនុប្រធានសហព័ន្ធសហជីពយុវជនខ្មែរ |
| ២-លោក សៀ សន | មន្ត្រីសហព័ន្ធសហជីពយុវជនខ្មែរ |
| ៣-លោក ញ៉ុក សុភ័ក្ត្រ | ប្រធានសហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន ឡុង លីដ |
| ៤-កញ្ញា ថោង ធឿន | អនុប្រធានសហជីព |

**បញ្ហាក្តុំខវិវាទ**

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១-ចំពោះកម្មករនិយោជិត ដែលធ្វើការបន្ថែមម៉ោងនៅថ្ងៃអាទិត្យ សុំឱ្យក្រុមហ៊ុនផ្តល់បាយថ្ងៃត្រង់មួយពេល ឬប្រាក់ ៣០០០ រៀល ។

២-សុំឱ្យក្រុមហ៊ុនដកអ្នកគ្រប់គ្រងចិននៅក្រុម ១ និងក្រុម ២ ចេញពីក្រុមនេះ ព្រោះគាត់ប្រើពាក្យសំដី និងអាកប្បកិរិយាមិនត្រឹមត្រូវជារៀងរាល់ថ្ងៃមកលើកម្មករ ។

**អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៥២៦ កប/កឆ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១។

**សវនាការ និង សង្ខេបនីតិវិធី**

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១១ (វេលាម៉ោង ៨:៣០ នាទី ព្រឹក)។

បញ្ហានៃនីតិវិធី:

នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំង បានផ្សះផ្សាវិវាទការងាររួមចំនួន ១២ ចំណុច ដោយបានទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ១០ ចំណុច ។ ចំណុចមិនសះជាចំនួន ២ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១ ។

បន្ទាប់ពីបានទទួលសំណុំរឿងនេះរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ២ ចំណុចនេះនៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១១ វេលាម៉ោង ០៨:៣០ នាទី ព្រឹក។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល តាមកាលបរិច្ឆេទ និងពេលវេលាកំណត់។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមស្វែងរកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ២ ចំណុចនេះបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ១ ចំណុច គឺចំណុចវិវាទទី២។ ដូច្នេះ ចំណុចវិវាទ ដែលនៅសល់សម្រាប់ការចេញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺចំណុចវិវាទទី១ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា និងដោះស្រាយ ដោយចេញសេចក្តីបង្គាប់លើចំណុចវិវាទទី១ ដែលមិនសះជាខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១-លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន ឡុង លីដ ជូនកញ្ញា ឯក ផាន់ណា និងលោក យឹម ជឿង ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១១ ។

២-លក្ខន្តិកៈក្រុមហ៊ុន ឡុង លីដ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ ។

៣-វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន ឡុង លីដ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩ ។

៤-បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ឡុង លីដ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១០ ។

៥-លិខិតរបស់សហព័ន្ធសហជីពយុវជនខ្មែរលេខ ២១០ សសយខ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១ គោរពជូនលោកនាយកក្រុមហ៊ុន ឡុង លីដ ស្តីពីការសុំជួបពិភាក្សា និងសម្រុះសម្រួលនូវករណីវិវាទការងាររបស់កម្មករនិយោជិត ។

៦-លិខិតពឹងពាក់ និងជួយអមរបស់កម្មករនិយោជិតក្រុមហ៊ុន ឡុង លីដ គោរពជូនលោកប្រធានសហព័ន្ធសហជីពយុវជនខ្មែរ ស្តីពីសុំពឹងពាក់ ជួយអម និងជួយសម្របសម្រួលដោះស្រាយជាមួយក្រុមហ៊ុន ក្រសួងការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាល តុលាការ អាជ្ញាធរ និងស្ថាប័នគ្រប់ជាន់ថ្នាក់ ដែលពាក់ព័ន្ធ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១១ ។

៧-កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ក្រុមហ៊ុន ឡុង លីដ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១ ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១-រូបថត ៤ សន្លឹក ។

២-លិខិតរបស់នាយកដ្ឋានវិវាទការងារលេខ ០២៥ កប/អក/វក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ជម្រាបមកលោកប្រធានសហជីពយុវជនខ្មែរក្រុមហ៊ុន ឡុង លីដ ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី ។

៣-ពាក្យបណ្តឹងរបស់កម្មករនិយោជិតឈ្មោះ ជា ម៉ាឡៃ, ប៉ា ចរិយ៉ា, សែម សាត, ខឿន ណេម, យោក មួន, វន ចន្ធី, ដួង ស្រីមុំ, វ៉ាត ស្រីនាង, ម៉ៃ ចន្ធី, វង់ ស៊ីពៅ សុំឱ្យក្រុមហ៊ុនដកចិនគ្រប់គ្រងនៅក្រុម ១ និង ២ ចេញពីក្រុមហ៊ុន ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១១ ។

៤-វិញ្ញាបនប័ត្រចុះបញ្ជិការសហជីពយុវជនខ្មែរក្រុមហ៊ុន ឡុង លីដ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១០។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១-របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ឡុង លីដ លេខ ៥២៦ កប/កន ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០១១។

២-កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ឡុង លីដ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១-លិខិតអញ្ជើញនិយោជកចូលរួមសវនាការលេខ ៦៣៤ កប/អក/វក/លកអ. ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១។

២-លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៦៣៥ កប/អក/វក/លកអ. ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០១១។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ឡុង លីដ ផលិតស្បែកជើង បានចាប់ដំណើរការជិតពីរឆ្នាំមកហើយ និងមានជួលកម្មករនិយោជិតសរុបចំនួន ១៦០០ នាក់។
- នៅក្នុងក្រុមហ៊ុនមានសហជីពតែមួយ គឺសហជីពយុវជនខ្មែរក្រុមហ៊ុន ឡុង លីដ ដែលជាដើមបណ្តឹងក្នុងសំណុំរឿងនេះ ហើយមានសមាជិកចំនួន ៤៦៩ នាក់ ដែលនិយោជកបានកាត់ប្រាក់ភាគទានសហជីព។

ចំណុចវិវាទទី១: ចំពោះកម្មករនិយោជិត ដែលធ្វើការបន្ថែមម៉ោងនៅថ្ងៃអាទិត្យ សុំឱ្យក្រុមហ៊ុនផ្តល់បាយមួយពេលដោយឥតគិតថ្លៃ ឬប្រាក់ ៣០០០ រៀល

- នៅក្នុងសវនាការ កម្មករនិយោជិតបញ្ជាក់ការទាមទារថា ពួកគាត់ទាមទារឱ្យនិយោជកផ្តល់បាយមួយ

ពេលដោយឥតគិតថ្លៃ ឬប្រាក់ថ្លៃបាយថែមម៉ោងចំនួន ២០០០ រៀល ចំពោះកម្មករនិយោជិត ដែលធ្វើការងារថែមម៉ោងនៅថ្ងៃអាទិត្យ។

- នៅក្នុងក្រុមហ៊ុន ឧស្សាហ៍មានការងារថែមម៉ោងណាស់ តួយ៉ាងនៅពេលថ្មីៗនេះ ក្នុងខែកក្កដា និងខែសីហា ឆ្នាំ២០១១ មានការងារថែមម៉ោងនៅរាល់ថ្ងៃអាទិត្យ ដែលជាថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍។ នៅរាល់ពេលមានការងារថែមម៉ោងនៅថ្ងៃអាទិត្យនេះ និយោជកផ្តល់ប្រាក់ឈ្នួលការងារថែមម៉ោងតាមច្បាប់ស្តីពីការងារ ប៉ុន្តែមិនបានផ្តល់បាយមួយពេលដោយឥតគិតថ្លៃ ឬប្រាក់ថ្លៃបាយថែមម៉ោងចំនួន ២០០០ រៀល ចំពោះកម្មករនិយោជិតទេ។ ដោយឡែកចំពោះការងារថែមម៉ោងនៃថ្ងៃធ្វើការធម្មតា និយោជកផ្តល់ជូនប្រាក់ថ្លៃបាយថែមម៉ោងចំនួន ២០០០ រៀល ចំពោះរាល់ការងារថែមម៉ោងចំនួនពីរម៉ោង។
- កម្មករនិយោជិតនៅតែទាមទារឱ្យនិយោជកផ្តល់បាយមួយពេលដោយឥតគិតថ្លៃ ឬប្រាក់ថ្លៃបាយថែមម៉ោងចំនួន ២០០០ រៀល ចំពោះកម្មករនិយោជិតដែលធ្វើការងារថែមម៉ោងនៅថ្ងៃអាទិត្យ ដោយផ្អែកលើសេចក្តីជូនដំណឹងលេខ ០៤១/១១ ក.ប/ស.ជ.ណ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១។
- ភាគីនិយោជកលើកឡើងថា គាត់បានយល់ពីខ្លឹមសាររបស់សេចក្តីជូនដំណឹងលេខ ០៤១/១១ ក.ប/ស.ជ.ណ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ នេះ ប៉ុន្តែ មិនទាន់មានលទ្ធភាពផ្តល់ជូន។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលភស្តុតាងមួយចំនួនពីភាគីនិយោជកនៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១១ ពោលគឺយឺតមួយថ្ងៃ ក្រោយកាលបរិច្ឆេទ ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលកំណត់ឱ្យផ្តល់ភស្តុតាង ដែលត្រូវផ្តល់នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១១។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនពិចារណាភស្តុតាងដែលដាក់ជូនហួសកាលកំណត់នេះទេ។

## ហេតុផលនៃសេចក្តីសម្រេច

**ចំណុចវិវាទទី១: ចំពោះកម្មករនិយោជិតដែលធ្វើការបន្ថែមម៉ោងនៅថ្ងៃអាទិត្យ សុំឱ្យក្រុមហ៊ុនផ្តល់បាយមួយពេលដោយឥតគិតថ្លៃ ឬប្រាក់ ២០០០ រៀល**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្តល់ប្រាក់ថ្លៃបាយចំនួន ២០០០ (ពីរពាន់) រៀលក្នុងមួយថ្ងៃ ឬផ្តល់ជូនបាយមួយពេលដោយឥតគិតថ្លៃ ដល់កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងនៅថ្ងៃអាទិត្យដែរ ឬទេ?

ចំណុចទី២ នៃសេចក្តីជូនដំណឹងលេខ ០៤១ សកបយ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ ចែងថា “*កម្មករនិយោជិត ដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងតាមសំណូមពររបស់និយោជក ត្រូវទទួលបានប្រាក់ថ្លៃបាយចំនួន ២០០០ (ពីរពាន់) រៀល ក្នុងមួយថ្ងៃ ឬទទួលបានការផ្តល់ជូនបាយមួយពេល ដោយឥតគិតថ្លៃ*”។

យោងតាមអង្គហេតុ ថ្ងៃអាទិត្យជាថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍របស់ក្រុមហ៊ុននេះ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការងារនៅថ្ងៃអាទិត្យ ជាការងារបន្ថែមម៉ោង។ ដូចនេះ តាមខ្លឹមសារនៃចំណុចទី២ នៃសេចក្តីជូនដំណឹងលេខ ០៤១ សកបយ ខាងលើនេះ កម្មករនិយោជិត ដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងតាមសំណូម

ពររបស់និយោជក ត្រូវទទួលបានប្រាក់ថ្លៃបាយចំនួន ២០០០ (ពីរពាន់) រៀល ក្នុងមួយថ្ងៃ ឬទទួលបានការផ្ដល់ជូនថ្លៃបាយមួយពេលដោយឥតគិតថ្លៃ ដោយមិនកំណត់ថា ធ្វើការថែមម៉ោងប៉ុន្មានម៉ោងទេ។

តាមអង្គហេតុ និយោជកមិនដែលផ្ដល់ជូននូវប្រាក់ថ្លៃបាយ ឬបាយមួយពេលដោយឥតគិតថ្លៃនេះដល់កម្មករនិយោជិត ដែលធ្វើការងារថែមម៉ោងនៅថ្ងៃអាទិត្យទេ។ ហេតុនេះ និយោជកត្រូវផ្ដល់ប្រាក់ថ្លៃបាយចំនួន ២០០០ (ពីរពាន់) រៀល ក្នុងមួយថ្ងៃ ឬផ្ដល់ជូនបាយមួយពេល ដោយឥតគិតថ្លៃ តាមសេចក្ដីជូនដំណឹងលេខ ០៤១ សកបយ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចបង្គាប់ឱ្យនិយោជកផ្ដល់ប្រាក់ថ្លៃបាយចំនួន ២០០០ (ពីរពាន់) រៀលក្នុងមួយថ្ងៃ ឬផ្ដល់ជូនបាយមួយពេលដោយឥតគិតថ្លៃ ដល់កម្មករនិយោជិត ដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងនៅថ្ងៃអាទិត្យ។

យោងតាមការបង្ហាញភស្ដុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចចេញសេចក្ដីបង្គាប់ដូចតទៅ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១៖**

បង្គាប់ឱ្យនិយោជកផ្ដល់ប្រាក់ថ្លៃបាយចំនួន ២០០០ (ពីរពាន់) រៀល ក្នុងមួយថ្ងៃ ឬផ្ដល់ជូនបាយមួយពេលដោយឥតគិតថ្លៃ ដល់កម្មករនិយោជិត ដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងនៅថ្ងៃអាទិត្យ។

ប្រភេទនៃសេចក្ដីបង្គាប់៖ សេចក្ដីបង្គាប់ជាប់កាតព្វកិច្ច

សេចក្ដីបង្គាប់នេះនឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្ដង បន្ទាប់ពីសេចក្ដីបង្គាប់នេះចេញទៅ ដោយសារភាគីទាំងពីរបានយល់ព្រមជ្រើសរើសយកសេចក្ដីបង្គាប់ជាប់កាតព្វកិច្ច នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ ២០១១។

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក៖**

ឈ្មោះ៖ **អ៊ុំង សុទ្ធី**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត៖

ឈ្មោះ៖ **លីវ សុវណ្ណា**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល៖

ឈ្មោះ៖ **រុន សារ៉ាយ**

ហត្ថលេខា: ------------------------------